# សេចក្តីជូនដំណឹង

**ជូនចំពោះ ៖** សមាជិកអង្គការគ.ស.ក/ម្ចាស់ជំនួយ/ដៃគូពាក់ព័ន្ធទាំងអស់

**កម្មវត្ថុ៖** ការពន្យាពេលនៃការធ្វើសកម្មភាពមួយចំនួនរបស់ អង្គការ គ.ស.ក

សូមគោរពជូន សមាជិកអង្គការគ.ស.ក/ម្ចាស់ជំនួយ/ដៃគូពាក់ព័ន្ធទាំងអស់

អស់លោក លោកស្រី អ្នកនាងកញ្ញា បានជ្រាបរួចមកហើយថា វីរុស កូរូណា ២០១៩ (កូវីដ-១៩) ត្រូវបានអោយឈ្មោះថាជា ជំងឺរាតត្បាតទូទាំងសកលលោក ដោយអង្គការសុខភាពពិភពលោក (WHO)។ ករណីនៃជំងឺរាតត្បាតនេះ ត្រូវបានកើតឡើងនៅក្នុងប្រទេសជាច្រើននៅលើពិភពលោក។ រហូតមកដល់ពេលនេះ រដ្ឋាភិបាលកម្ពុជាបានប្រកាសថា កម្ពុជាបានរកឃើញអ្នកដែលឆ្លងមេរោគ កូវីដ-១៩ មានចំនួន ៥ករណីមកហើយ ។

ដោយមានការណែនាំ ពីរដ្ឋាភិបាលកម្ពុជា អង្គការសុខភាពពិភពលោក (WHO) និង ការណែនាំ ពី គណៈកម្មាធិការប្រតិបត្តិ របស់អង្គការ គ.ស.ក និងក៏ដើម្បីសុវត្ថិភាពរបស់អស់លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ អង្គការ គ.ស.ក សូមគោរពជូនដំណឹងថា រាល់ព្រឹត្តការណ៍ធំៗដែលនឹងត្រូវបានរៀបចំឡើងក្នុងកំឡុងខែ មិនា និងខែមេសា ឆ្នាំ២០២០ ដូចជា ការប្រជុំប្រចាំឆ្នាំ ខួបទី ៣០ របស់អង្គការ គ.ស.ក ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៦ មិនា ២០២០ វេទិការសិក្សារៀនសូត្រអំពី ធនធានមនុស្ស ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២០ ខែមិនា ឆ្នាំ២០២០ និង វេទិការរៀនសូត្រអំពីហិរញ្ញវត្ថុដែលនឹងប្រព្រឹត្តទៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០នឹងត្រូវបានពន្យាពេលទាំងអស់។

អង្គការ គ.ស.ក នឹងជូនជាព័ត៌មានបន្ទាប់ទៀត អំពីកាលបរិច្ឆេទថ្មីនៃការប្រារព្ធកម្មវិធីទាំងអស់នេះ។ តែទោះបីជាយ៉ាងណា អង្គការ គ.ស.ក នឹងនៅតែបន្ត ធ្វើកិច្ចការងារជាមួយអស់លោក លោកស្រី អ្នកនាងកញ្ញា ទាំងអស់គ្នាជាលក្ខណៈក្រុម ឬព្រឹត្តិការណ៍តូចៗ ជាមួយនឹងការតាមដានអំពីបច្ចុប្បន្នភាពនៃ វីរុស កូវីដ-១៩ នេះដោយប្រុងប្រយ័ត្ន ឬដោយជំនួសដោយការធ្វើការ ជាលក្ខណៈ វេទិការ អនឡាញ បើអាចទៅរួច។ ដើម្បី ទទួលបាននូវព័ត៌មានអំពីបច្ចុប្បន្នភាព នៃ វីរុស កូវីដ-១៩ អស់លោក លោកស្រី អ្នកនាងកញ្ញា អាចចូលទៅកាន់តំណខាងក្រោម៖

http://cdcmoh.gov.kh/ and/or https://www.who.int/emergencies/diseases/novel-coronavirus-2019



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability
25/08/2015 GPP 24/08/2018
Symbol of Trust

អង្គការ គ.ស.ក សូមថ្លែងអំណរគុណអស់លោក លោកស្រី អ្នកនាងកញ្ញា ទាំងអស់ ដែលតែងតែនៅបន្ត គាំទ្រនូវរាល់បេសកកម្ម និងអាណត្តិរបស់របស់អង្គការ គ.ស.ក យើងខ្ញុំ។ យើងខ្ញុំសូមអធ្យាស្រ័យចំពោះអស់លោក លោកស្រី អ្នកនាងកញ្ញា ទាំងអស់នូវរាល់បញ្ហាទាំងឡាយ និងការអាក់ខាន ឬពន្យាពេល រាល់សកម្មភាពដែលបានរៀបរាប់ដូចខាងលើ។

អាស្រ័យដូចបានជម្រាបជូនខាងលើ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា អស់លោក លោកស្រី អ្នកនាងកញ្ញា នៅតែបន្តកិច្ចសហការ យ៉ាងសកម្ម និងដោយក្តីរីករាយ ។

ថ្ងៃសុក្រ ៥រោច ខែផល្គុន ឆ្នាំកុរឯកស័ក ព.ស ២៥៦៣
ត្រូវនឹងថ្ងៃទី១៣ ខែមិនា ឆ្នាំ២០២០

**លោកស្រី ត្រីស្ទិន រ៉ាស់មូសសិន**
**ប្រធានគណៈកម្មាធិការប្រតិបត្តិ**
អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា

**លោក សឿង សារឿន**
**នាយកប្រតិបត្តិ**
អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា